# សេចក្តីជូនដំណឹង
# អំពី
# សន្និសីទជាតិស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

ធនាគារជាតិនៃកម្ពុជានឹងរៀបចំសន្និសីទជាតិស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជានៅថ្ងៃទី ១៤-១៥ ខែមីនា ឆ្នាំ២០១៦ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរំឭកខួប ១០ឆ្នាំបន្ទាប់ពីរាជរដ្ឋាភិបាល បានប្រកាសថា "ឆ្នាំ២០០៦ជាឆ្នាំមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" កន្លងមកនេះ និងដើម្បីផ្សព្វផ្សាយ សមិទ្ធផលដែលសម្រេចបាននារយៈពេលកន្លងមកនិងទាក់ទាញការចាប់អារម្មណ៍បន្ថែមពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិអំពីសារៈសំខាន់អត្ថប្រយោជន៍ និងតួនាទីរបស់វិស័យមីក្រូហិរញ្ញវត្ថុ ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងកាត់បន្ថយភាពក្រីក្រដែលជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ។

កម្មវិធីបើកសន្និសីទជាតិនឹងប្រព្រឹត្តទៅនៅព្រឹកថ្ងៃទី១៤ខែមីនា ឆ្នាំ២០១៦ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រីក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ កម្មវិធីបន្ទាប់នៅល្ងាចថ្ងៃទី១៤និងនៅថ្ងៃទី១៥ខែមីនាឆ្នាំ ២០១៦នឹងត្រូវប្រារព្ធនៅ City Hallកោះពេជ្រ ។សន្និសីទរយៈពេល ២ថ្ងៃ នេះនឹងបង្ហាញនូវវឌ្ឍនភាពនិងការអភិវឌ្ឍនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ក្នុងរយៈពេល ១០ឆ្នាំ កន្លងមក (២០០៦-២០១៦) ព្រមទាំងមានកិច្ចពិភាក្សាលើប្រធានបទចំនួន ៥រួមមាន៖ទី១/- "លទ្ធភាពក្នុងការប្រើប្រាស់និងទទួលបានសេវាហិរញ្ញវត្ថុ" ទី២/-"ការឲ្យខ្ចីក្នុងនិងក្រៅប្រព័ន្ធ"ទី៣/- "ចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងកិច្ចការពារអតិថិជន" ទី៤/-"សេវាធនាគារចល័ត៖ឱកាសនិងការប្រឈម" និងទី៥/-"តួនាទីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងសកម្មភាពសង្គមនិងបរិស្ថាន" ។កិច្ចពិភាក្សានេះនឹងមានការចូលរួមពីវាគ្មិនជាតិនិងអន្តរជាតិមកពីក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍វិស័យឯកជនអង្គការអន្តរជាតិ និងភាគីពាក់ព័ន្ធផ្សេងៗ។

ទន្ទឹមនឹងដំណើរការនៃសន្និសីទនេះក៏មានការរៀបចំកម្មវិធីតាំងពិព័រណ៍និងការប្រគុំតន្ត្រីពេលល្ងាចចំនួន៤ថ្ងៃដែលប្រារព្ធធ្វើឡើងជូនសាធារណជនទស្សនាកំសាន្ត ចាប់ពីថ្ងៃ១២-១៥ខែមីនាឆ្នាំ២០១៦នៅបរិវេណCity Hallកោះពេជ្រ ផងដែរ។